រាស្ត្រគឺគំនិតចក្រពត្តិ គំនិតមើលងាយមនុស្ស ( ចាស់មើលងាយក្មេង ប្រុសមើលងាយស្រី អ្នកធំមើលងាយអ្នកតូច អ្នកមានមើលងាយអ្នកក្រ) គំនិតលុតក្រាប គំនិតប្រកាន់បក្សពួកហួសហេតុ គំនិតសក្តិភូមិនិយម ។

អាស្រ័យហេតុនេះ អ្នកនិពន្ធគប្បីកត្រង់បញ្ហាតែងរឿង ទោះជារឿងប្រលោមលោកសាមញ្ញក្តី ទោះជារឿងប្រលោមលោកក្នុងប្រវត្តិសាស្ត្រក្តី ឲ្យយ៉ាងណាឲ្យជនរួមជាតិ មានសតិសម្បជញ្ញៈភ្ញាក់រឭកឡើង ដឹងខ្លួនថា ជាមនុស្ស មនុស្សមានសិទ្ធិស្មើមនុស្សឯទៀត មានសេរីភាពតាមបែបមានសកលលោក និង លទ្ធិប្រជាធិបតេយ្យ ។

ធ្វើយ៉ាងនេះ គឺជួយដំណើរការអ្នកនយោបាយ (មានរាជរដ្ឋាភិបាលជាដើម ) ឲ្យងាយក្នុងការរៀបចំសង្គមយើង ឲ្យមានវឌ្ឍនធម៌ និង សន្តិភាពដែលមនុស្សលើសកលលោកស្រឡាញ់គ្រប់ ៗ គ្នា ។

សាន សាងាត

*ភ្នំពេញ ឆ្នាំ ១៩៥៨*



# ខ្លាបាក់ចង្កូម

ផ្ទះនោះទាបប្រក់ស្បូវ ជញ្ជាំងក្តារ សង់លើដីទួលតូច តែស្អាតមានរបងអំពិលទឹកព័ទ្ធជុំវិញ ។

ខាងមុខ គឺផងស្ទឹងនៃអាណាខេត្តសិរីសោភ័ណ · ដែលក្នុងឆ្នាំ ១៩៥៥ នេះ គង្គាហូរគំហុកយ៉ាងខ្លាំង ហាក់សំដែងសេចក្តីក្រោធខឹងនឹងអំណាចសៀមដែលសង្កត់សង្កិនយូរមកហើយ ។ ខាងក្រោយ គឺផ្លូវភ្នំស្វាយដែលលាតសន្ធឹងទៅឆ្ងាយដល់ទឹកដែនមេ ។

ក្នុងផ្ទះនេះនៅមានចង្កូម មនុស្សម្នាក់អង្គុយផ្អែកខ្នងលើកៅអីផ្តៅធំមួយសម្លឹងមិនព្រិចភ្នែក មើលទៅគេហដ្ឋានមួយទៀត ដែលល្អដើក ឆាយបីផ្លូវមានទីស្នាក់ការសត្តាល័យ ។

មនុស្សនេះចាស់សក់ស្កូវ ពុកចង្កាស្រមមួសក្បាល ហាក់អាយុប្រមាណចិតសិបប្លាយឆ្នាំ ។

មើលរាងកាយ មើលគិនភាគ យើងអាចសន្និដ្ឋានបានថា ពុំមែនជាមនុស្សសាមញ្ញទេ គឺប្រាកដជាមនុស្សម្នាក់ពិសេសដោយឡែកមិនខាន ។

គាត់មានសម្បុរខ្មៅដែង ។ សម្បុរនេះបង្ហាញជីវិតរបស់គាត់ឲ្យយើង



ពីងថា គាត់ពុំមែនជាមនុស្សជិះជាន់គេដែលស្រណុកនៅតែក្នុងម្ហូប ចាំតែគេបម្រើឡើងស្ដាំនោះទេ ។ សម្បុរនេះជាសម្បុរមនុស្សលំបាក ហាលខ្យល់ ហាលថ្ងៃ ហាលភ្លៀង ជាមនុស្សពុះពារប្រឹងប្រែងតស៊ូ មានប្រជែងរកយុត្តិធម៌ និងសុភមង្គលជូនប្រទេសជាតិ និងប្រជាជនខ្មែរយើង ។

*ហេតុនេះ តាចាស់យើងជាមនុស្សមានឧត្តមគតិខ្ពស់ ! !*

ផ្ទះគាត់ធំទូលាយ ។ នៅលើជញ្ជាំងនេះ យើងហាក់មើលឃើញរូបនៃការពិសោធន៍ ។ ដែលបោះបង្គោលជិតជាប់នៅនោះ រូបដែលនាំឲ្យយើងកើតមានសទ្ធាចិត្តមួយគោរពសរសើរដល់តាត់យ៉ាងជ្រាលជ្រៅបំផុត ។

កាលណាយើងគយគន់គាត់ឲ្យយូរបន្តិចទៅទៀត យើងស្ទើរតែភ្លេចផ្សែងផ្កាដែលលោកបន្ទាត់យ៉ាងឆ្ងាញ់ស្រវាំនៅលើជញ្ជាំងនោះ ។ ផ្ទុងផ្សែងទាំងនោះ និយាយប្រាប់យើងនូវអនុស្សាវរីយ៍ដ៏វិចិត្រផ្សេង ។ ដែលគាត់បានជួបប្រទះក្នុងដំណើរជីវិតរបស់គាត់មានអនុស្សាវរីយ៍នៃសេចក្ដីស្នេហា អនុស្សាវរីយ៍នៃសេចក្ដីសប្បាយ អនុស្សាវរីយ៍នៃគ្រោះថ្នាក់ ។

អនុស្សាវរីយ៍ទាំងនោះ ជាគំរូនៃជីវិតដែលអាចត្រូវសាងបានជារឿងមួយយ៉ាងជក់ចិត្តដល់យុវជន ដែលស្រឡាញ់ការផ្សងព្រេងពិលាក ដូចរឿងផ្សេងៗក្នុងសៀវភៅប្រលោមលោកធំ ។ នៃប្រទេសនានាក្នុងកាលសម័យបុរាណ ។

ទឹកមុខរបស់តាចាស់យើង មើលឃើញគួរសមខ្សឹម សម្បុរក្រាំ គាត់មានស្លាកខ្វា មិនស្អាតមុត ។ តែបើយើងធ្លាប់ស្គាល់គាត់ យើងមុខជាស្រឡាញ់គាត់វិញ ពីព្រោះគាត់ជាមនុស្សស្លូត ចិត្តត្រង់ ចេះអាណិត ចេះជួយសង្គ្រោះដល់អ្នកក្រីក្រគ្រប់ ៗ គ្នា មិនថាស្រី ឬ ប្រុស ក្មេងចាស់ទេ ។ ម្យ៉ាងទៀត គាត់ជាមនុស្សមានវោហារពូកែ មានប្រាជ្ញាវៃឆ្លាតណាស់ក្នុងការដោះស្រាយបញ្ហា មិនមានសតិរឹងប៉ឹងចំពោះឧបសគ្គទាំងពួង ។

« *វិសេសក្លាហាន* » នេះហើយឈ្មោះគាត់ ។

មេទ័ពជើងចាស់ វិសេសក្លាហានបានចូលបម្រើប្រទេសជាតិ ជាទាហានតាំងពីខ្លួននៅក្មេងពេញវ័យនៅឡើយ ។ ដោយចិត្តស្នេហាមាតុភូមិយ៉ាងជ្រាលជ្រៅ ដោយពលិកម្មមានការលះបង់ក្តីសប្បាយ កាមរាគ ល្បែងស៊ីសង ស្រី ស្រាផាផឹក ដើម្បីបំពេញកិច្ចការសាធារណៈឱ្យបានហ្មត់ចត់ល្អ ដោយសតិសម្បជញ្ញៈ ចេះត្រិះរិះស្គាល់ខុស ស្គាល់ត្រូវ ដោយមានចិត្តជាមនុស្សសេរី មិនរវល់លុតក្រាបនឹងសំពះអង្វរអ្នកណាដើម្បីបុណ្យសក្តិខ្លួន វិសេសក្លាហានបានឡើងបុណ្យសក្តិជាលំដាប់ រហូតដល់បានជាមេទ័ពជាតិទាំងមូល ។

កាលនោះមានកម្លាំងមនុស្សនៅឡើយ វិសេសក្លាហានបានចូលប្រឡូកគ្រប់សង្គ្រាមទាំងអស់ រួចក្នុងសង្គ្រាមនីមួយ ៗ ជាមួយយួនក្តី ជាមួយសៀមក្តី ជាមួយលាវក្តី វិសេសក្លាហានមានស្នាដៃសក្តិសំឡេងឈ្មោះពីរោះប្រកបដោយជោគជ័យជានិច្ច ។



តែដល់សម័យគាត់ចូលក្នុងវ័យជរាពិការនេះ ស្រុកចុះដុនដាប ខ្មែរបែកសាមគ្គី អ្នកកាន់អំណាចខ្មែរមានចិត្តទន់ខ្សោយ ធ្វើការគ្មានកម្មវិធី រាស្ត្រអត់បាយ ខ្វះចូលរុករានពាសពេញ វិសេសក្លាហានក៏ថយខ្លួនមកនៅក្នុងភូមិកំណើតដែលយើងបានពណ៌នាមកហើយនេះ ។

រាល់ថ្ងៃ វិសេសក្លាហានភ្ញាក់ពីព្រលឹមអង្គុយសំឡឹងគេហដ្ឋានដែលគាត់មើលឃើញតាមបង្អួចនេះ ។

គាត់មានចិត្តទោមនស្សក្រៃពេក ។ ម្ចាស់គេហដ្ឋានដ៏ស្តុកស្តម្ភនោះឈ្មោះ « ព្រះកម្ពុត » ។ គឺជាខ្មែរមួយរូបដែរ ដែលបានទៅរៀននៅខាងសៀម រួចបានក្លាយជាតិខ្លួនទៅជាជាតិសៀម ភ្លេចទឹកនាដល់អរិយធម៌ខ្មែរដល់កិត្តិយសខ្មែរ ដល់កិត្យានុភាពខ្មែរស្ទើរលិច រួចគិតតែធ្វើបាបដល់រាស្ត្រខ្មែរ មានការចាប់ចង កំហែងគំរាម កេណ្ឌចូន កាប់សម្លាប់ខ្មែរគ្នាឯងជាដើម ។

តាំងពីព្រះកម្ពុត មកគ្រប់គ្រងអាណាខេត្តសិរីសោភ័ណ តាងនាយរដ្ឋាភិបាលសៀមនេះ ព្រះកម្ពុតរស់នៅក្នុងការសប្បាយ ( ស្រី ស្រា ល្បែង ភ្លេងភ្ជាប់ច្រៀងរាំ ) គ្រប់បែបគ្រប់យ៉ាង ហើយប្រើលទ្ធិផ្តាច់ការលើខ្មែរយើង ។ ប្រជានុរាស្ត្រក៏បានស្គាល់នូវទុក្ខវេទនាក្រៃពេក ឥតមានពេលណាមកប្រៀបប្រដូចបានឡើយ ។ ម្យ៉ាងទៀតក្នុងការគ្រប់គ្រងនេះ ព្រះកម្ពុតគិតតែប្រមូលធនធានទ្រព្យសម្បត្តិសម្រាប់តែខ្លួនមួយប៉ុណ្ណោះ ។

ដោយហេតុនេះ ចំពោះប្រាសាទដ៏ល្អឆើតឆាយដែលវិសេសក្លាហានមើលឃើញនេះ បើអ្នកមើល ៗ មិនឃើញរឿង មុខជាកោត

សរសើរដល់គុណគ្រោងសំណង់របស់ព្រះកម្ពុជាមិនខាន ។

តែកាលដែលវិសេសក្លាហានមើលប្រាសាទនោះ ឃើញជាភ្លើង ជាសាច់ ជាឈាម ជាញើស ជាកម្លាំងរបស់ប្រជាជនខ្មែរទៅវិញ ។ ប្រាសាទនេះហាក់ឈរយ៉ាងក្រអឺតដាក់គាត់គ្មានខ្វាសគ្មានអៀនឡើយ ។

ដោយគាត់ចាស់ហើយ ដែលគាត់កាន់អាវុធទៀតពុំកើត ជើងគាត់ដើរទៀតលែងបាន មាត់គាត់ប្រាសចាកអស់សំឡេង គាត់ហាក់ឃើញតែនូវភាពបុរាណរបស់គាត់ទ្រុឌទ្រោម ពីមុខភ្នំអយុត្តិធម៌របស់ព្រះកម្ពុជ ។ នៅក្នុងទ្រូងវិសេសក្លាហាននៅមានតែកម្លាំងចិត្ត កម្លាំងបញ្ញា ទេ ដែលរស់រវើកក្នុងខ្លួនគាត់ ហើយដែលជាហេតុនាំឲ្យគាត់ចំបែង រាល់ពេលវេលា ។

មួយថ្ងៃ ។.គាត់សំឡឹងគេហដ្ឋាននោះដោយចេតនាចង់ឲ្យរលាយ ចង់ឲ្យឆេះចង់ឲ្យបាត់វិនាសសូន្យឈឹងទៅ ។

ប្រាសាទព្រះកម្ពុជហាក់ធ្ងន់លើចិត្តវិសេសក្លាហានអ្វីម៉េះទេ ពី ព្រោះប្រាសាទនេះសាងលើដីខ្មែរ និង សាងលើស្មារាស្ត្រខ្មែរ ។

ទឹកភ្នែកពីរដំណក់យ៉ាងល្វីងចត់ ហូរធ្លាក់ពីនេត្រវីរបុរសយើង ។

*ឱ ! វិសេសក្លាហានអស់ឫទ្ធានុភាពហើយ ។ គាត់*

*ខ្វាតាក់ចង្អុម ។*

យើងមានចិត្តមេត្តាដល់ចាស់ព្រឹទ្ធាចារ្យពិសេសមួយនេះជាពេក ។

សព្វថ្ងៃគាត់ក្រគ្មានទ្រព្យសម្បត្តិ គ្មានធនធាន គ្មានបាយហ៊ូប



គ្រប់គ្រាន់ គ្មានប្រដាប់ប្រដាប្រើប្រាស់សមរម្យ គ្មានខោអាវស្លៀកពាក់ គួរសម គ្មានលុយកាក់ចាយវាយ គ្មានភូមិអាករ កំព្រាម្នាក់ឯងគ្មានទីពឹង ។ រឿងវិសេសក្លាហានផ្ទុយនឹងរឿងស្នេហាជាតិឯទៀតជាច្រើនរូប។

តែវិសេសក្លាហានពុំមានអារម្មណ៍ចិត្តអ្វីនឹងឋានៈកំសត់ទុគ៌តនេះទេ គាត់នឹកថា គាត់អាចបិទភ្នែកស្លាប់ទៅវិញបានដោយសតិសម្បជញ្ញៈ របស់គាត់នៅស្អាតគ្មានបន្ទោសអ្វីដល់គាត់ឡើយ ។ គាត់អាចស្លាប់ ទៅវិញបានព្រោះផ្លូវដែលគាត់ជ្រើសរើសដើម្បីដើរ គឺផ្លូវថ្លៃថ្នូរប្រកប ដោយកិត្តិយសពិត ។ ។

ទឹកមុខរបស់ វិសេសក្លាហានមានទឹកមុខញញឹមយ៉ាងស្រគាលស្រគំ ឡើងវិញ ។

ក្នុងពេលនោះ ស្ត្រីម្នាក់ដើរចូលមកជុំសផ្ទះសំរាកគុម ។ គឺជា មនុស្សម្នាក់អាយុប្រមាណជាងសែសិបឆ្នាំ ។ នាងនោះបើកទ្វារក្រាក ។ វិសេសក្លាហានភ្ញាក់ខ្លួនព្រើត នៅស្ងៀមមួយស្របក់ ទើបមានវាចាសួរ ថា :

- អ្នកណា ? ក្មួយ ?
- ចាះ ! ខ្ញុំ ។
- ក្មួយ ! តើទៅរកឲស្រីខ្ញុំនៅណាហើយ ?

នាងនាសើចញញឹមពីក្រោយខ្នងវិសេសក្លាហានរួចហើយតបវិញថា :

- ចាះ ! នាងទៅលេងផ្ទះក្រោយផ្ទះហើយ ពីព្រោះថ្ងៃនេះជាថ្ងៃ

សំលេង ។

- កាលណាវាមកវិញ ?

- ចា៎ះ ! ដំរាបប្រសាសន៍ ប្រហែលមិនយូរប៉ុន្មានទេ . . .

នាងរំលងពាក្យអ្វីទៀតដែលគួរសោះ ។ នាងក៏បន្តការផ្ចិតផ្ចង់ទៅទៀតព្រោះតែព្រះស្រឡះ ទើបត្រឡប់ទៅក្នុងវិញបាត់ទៅ ។

វីរវិសេសក្លាហាន កាលនិយាយដល់ឈ្មោះកញ្ញា " ទេវី " ជាបុត្រី ចិត្តស្នេហាបុត្រមួយយ៉ាងខ្លាំងរត់ចូលឈៀបមកដល់ក្នុងបេះដូងគាត់ ។ ទឹកមុខស្លូតពីមុនមកក៏ប្រែក្លាយជារីករាយប្រិមប្រិយ៍ទៅវិញ ។ រូបលក្ខណ៍កល្យាណលេចឡើងចេញមកក្នុងមនោគតិគាត់ ។ គាត់ហាក់ឃើញស្រីនោមសាច់សល្អផូរផង់ ថ្ពាល់ខួច មុខស្រស់ ភ្នែកនិងបបូរមាត់មានសម្ផស្ស ចង្កេះរៀវ ដំណើរសមសួន ល្អផុតគេរបស់នារីទាំងពួង ។

ក្នុងពេលដ៏ខ្លីនេះ ព្រលឹងវិសេសក្លាហានអណ្តែតទៅបបោសអង្អែលរូបទេវីជាបុត្រីដែលទើបមានអាយុ ១៥ ឆ្នាំគត់ ។ សន្តានចិត្តគាត់កើតបរិតឹមួយយ៉ាងគ្រលួចក៏ឈានដំហានមកប្រជែងកន្លែង សេចក្តីស្នេហានៃបុត្រីដែលមានអម្បាញ់មិញនេះ ។

តើក្នុងណាងអ្វីក៏ដាក្រក់ម្ល៉េះ កញ្ញាល្អវិចិត្រនេះម្តេចមកកើតចំអន្ទង់សេចក្តីក្រទៅវិញ ? ។ វិសេសក្លាហានដកដង្ហើមធំក្នុងស្ងៀម ។ ទៅថ្ងៃមុខតទៅគាត់ពុំដឹងជាស្រ្តីឧត្តមរតនុត្តរនេះទាល់យ៉ាងណាទេ ? ពុំដឹងជានាងទៅទីណាទៀតណាទេ ? ឱ ! គួរគាប់គួរតានអ្វីទៀតសោះ ។ រាល់ថ្ងៃចំណងដែលចងជីវិតវិសេសក្លាហាននៅរស់នៅ គឺនារីប្រសើរនេះ





ឆាៗ នាងជារូប ជាចិត្ត ជាព្រលឹង ជាជីវិត ជាទីសង្ឃឹមរបស់គាត់ ។ ថ្ងៃនេះជាថ្ងៃសីលនាងទៅបេះផ្កា នាងលួចផ្កាកំពុងរីក នាងក្រសួបផ្ការផ្កា ។ នាងថ្វាយបង្គំព្រះ តែនាងប្រណម្យ ជីវិតនាងរស់តែក្នុងធម៌ ក្នុងមេត្តា ក្នុងកុសល ។ នាងមានសំដីផ្អែមពីរោះ ពុំដែលចេះទិតៀនគេសល់ទៅដែរ ស្តីអ្នកណាឡើយ ។

ដោយផ្ទៃនាងគតលាតត្រូវផាត់ឡើង ពុំបានរុងរឿងសោះនោះ វិសេសក្លាហានមានទុក្ខព្រួយជាខ្លាំងណាស់ ។ គាត់នឹកថា ទេវតាថ្ងៃមុនអ្នកមកសួរទុក្ខជាមួយយកភ្ញៀវទេវី គឺព្រោះនាងក្ខុង ពីព្រោះនាងក្ខុងជាមាសីដែលបានប៉ះពាល់ដោះនាងទេវី ។ នាងក្ខុងស្រឡាញ់នាងទេវីដូចកូនបង្កើត ។ នាងក្ខុងពុំដាច់ចិត្តទោសកាចោលនាងទេវីសោះ ហើយត្រូវរស់ដោយរល់ចាកផាមួយនាង ដើម្បីជួយមើលរក្សានាង ដើម្បីបានមើលមុខនាង ។

ដោយនឹកឃើញដូច្នោះ វិសេសក្លាហានអាណិតនាងក្ខុងក្រៃពេករកគ្មានអ្វីមកប្រៀបផ្ទឹមស្មើគ្មាន ។

× × ×



# បងប្អូនពីរនាក់

ព្រះសុរិយារោចលពន្លឺពណ៌មាសមកលើសិរីសោភ័ណ បីដូចប្រាប់ថា ព្រឹត្តិការណ៍មួយយ៉ាងចម្លែកនឹងចាប់កើតមានពីថ្ងៃនោះតទៅមិនខាន ។

ស្រីស្រស់ទេវី បុត្រីវិសេសក្លាហានដើរពីគុម្ពផ្កាមួយទៅគុម្ពផ្កាមួយៗ ។

ព្រឹកនោះ ធម្មជាតិដូនទេសភាពមួយជាទីពេញចិត្តបំផុត ។ ផ្កាមានស្លឹកពណ៌បៃតងខ្ចី ត្រសាងផ្លែមួយយ៉ាងធំទូលាយមួយទៅណើលសុធា ។ នៅចុងស្លឹកនីមួយៗ នៅចង្កាងនីមួយៗ នៅក្បែរមែកនីមួយៗ គឺបុប្ផពណ៌ ស លឿង ខៀវ ក្រហម ស្វាយ រីករោលរំពង់នេះត្រង់នោះ គ្រប់បែបគ្រប់យ៉ាង ខ្លះមានរំយោលពើតឆ្ងាយ ខ្លះមានទងជាក្បាច់ជាក្បូរ ដែលធ្វើឲ្យចក្ខុមនុស្សលោកឃើញចម្លែកស្រពកស្អុះស្អាវ ចង់ឲ្យតែមនុស្សជាតិយកទៅ មើលមិនចេះអស់មិនចេះហើយ ។

ឱ ! ស្មាដៃធម្មជាតិដែលចេះតុបតែងលោក តើអ្នកកើតឡើងសម្រាប់តែទេវីបុត្រីវិសេសក្លាហានម្នាក់ឯងឬ ? ឬសម្រាប់អ្នកទាំងអស់គ្នា ?

អ្នក និង កញ្ញាទេវីហាក់ចេញតែពីគុម្ពមួយ ពីព្រោះល្អពេកឆាយផុតវិស័យដូចគ្នា ។

នាងទេវីដើរមួយៗ យ៉ាងស្រាលខ្លួន ។ ស្រីស្រស់ក្រឡេកមើលនាយអាយ លបចំរើសផ្កាណាដែលនាងស្រឡាញ់ ។ នាងបេះផ្កាមួយយកមកសៀតលេងនឹងសក់នាង ។ នាងយកមកល្បងសៀតលើត្រចៀកនាង រួចយកមកដាក់ផ្ទឹមនឹងមុខនាង ។ នាងរីកតែញញឹមជាងមុនទៅទៀត ។

នារីសប្បាយរីករាយក្នុងចិត្តឥតឧបមា ។

ក្នុងមួយវិនាទីដ៏សុខសាន្តនេះ ដី ស្មៅ ឈើ ផ្កា ទឹក មេឃ ធម្មជាតិទាំងមូលគឺជាទ្រព្យរបស់នាងទាំងអស់ដែលមាននាងជាព្រះខត្តិយានីយ៍ម្ចាស់ស្រីតែមួយ ។

តាំងពីតូចមក នាងពុំដែលបានសប្បាយថ្ងៃណាមួយដូចថ្ងៃនោះឡើយ ។

នាងជាស្រីធ្លាប់តែរស់នៅក្នុងបរិវេណរបងផ្ទះ ក្នុងជញ្ជាំងស្វិតក្រៀមទាំងបួនជុំវិញ ។ ក្រៅពីព្រំដែនដែលបងជាភ្នែកមើលឃើញហើយកាត់បាននោះ នៅមានរបងដែកមួយរបងទៀតដែលភ្នែកធម្មតាមើលមិនឃើញឡើយ គឺរបងទំនៀមទម្លាប់ ។

វិញ្ញាសានេះ ចងក ចងដៃ ចងជើង ចងចិត្តនាងមិនឲ្យទៅណាបានឆ្ងាយពីខ្លួននាងឡើយ ។ *ហេតុនេះ ជីវិតនៃស្រីកល្យាណ គឺជាជីវិតក្នុងរូង ក្នុងរណ្ដៅ ងងឹតក្នុងកន្លែងឃុំឃាំង បំផុតជីវិតមនុស្សទោស* ។

ក្នុងមួយរពាចិត្ត ទាល់តែចំថ្ងៃសីលទើបនាងបានចេញដើរម្ដង ដោយមានកិច្ចបេះផ្កាជាហេតុ ។ ក្នុងពេលសេរីដ៏ថ្លៃថ្លានេះ កញ្ញា



ហាក់បានធ្វើសាច់ផ្ការឈាមផ្ការសរសៃ ដោយបានដកដង្ហើមយកខ្យល់ថ្មីក្នុងទីសួនច្បារ ។

ហេតុនេះ ថ្ងៃសីលចំពោះនាង គឺថ្ងៃរួចខ្លួន ថ្ងៃថ្មី ថ្ងៃសប្បាយ ថ្ងៃមនុស្ស ថ្ងៃស្មើមុខ ថ្ងៃសិទ្ធិ ថ្ងៃសេរី ។

កញ្ញាបេះបុប្ផាគ្រប់ពណ៌បានមួយដុំធំ ។ នាងបត់ជើងលើស្មៅ ។ នាងក្រងផ្កា នាងញញឹម នាងភ្លេចភ្នែក ចិត្តស្រីស្រមៃនឹក . . . នឹក . . . នាងនឹកដល់គូស្នេហារបស់នាង ម្ដេចបាត់យូរម្ល៉េះមិនឃើញមក ? តើប្រុសជីវិតទៅណា ? តើថ្ងៃនេះគូរវល់មានការអ្វី ? តើថ្ងើមឆ្នើមផុតអស់ប្រុសឈឺហើយឬដូចម្ដេច ? តើសង្សារប្រសើរភ្លេចនាងឬ ? តើព្រលឹងបងស្នេហាប្អូន ដូចប្អូនស្នេហាបងឬទេ ? តើគូស្នេហាហ៊ានប្ដូរជីវិតនឹងប្អូន ដូចប្អូនហ៊ានប្ដូរជីវិតនឹងបងឬទេ ?

ចំណោទទាំងប៉ុន្មាននេះ ហូរមកប៉ះដួងចិត្តនាងទេវីស្រីកំសត់បន្ត-បន្ទាប់គ្នាគ្មានឈប់ឈរសោះ ។

ក្នុងពេលនោះ ប្រុសម្នាក់មាឌធំ ស្វាគូលាយ ដើមទ្រូងធំ ចង្កេះរៀវ សក់រួញអង្កាជី មុខស្រស់ភ្នែកមុតថ្លា សម្លៀកបំពាក់រុងរឿងអារ-ពណ៌ខៀវលើបរលោងជាប់ស្រោមពាក្យសប្បុរសនៅចង្កេះ សមជាអ្នកមានបណ្ដាស័ក្តិខ្ពង់ខ្ពស់ អាយុប្រមាណជាង ២០ ឆ្នាំ ស្ទុះភ្លាត់ចេញពីគុម្ពផ្កាមួយ រហ័សដូចឆ្មាមកចាប់នឹងនាងទេវីពីក្រោយរឹតជាប់ដូចផ្កាប់នឹងមុខចុះថើប . . . ។

ទេវីដំបូងភ្ញាក់ដូចគេកន្ត្រាក់ ប៉ុន្តែលុះនាងនឹងនៃជួបគ្នា មុខទល់មុខដល់

ផ្កាប្រាមនាងរារឹតតប្រុសចម្លែកជើងឆើតនេះយ៉ាងខ្លាំងបន្ថែមទៅទៀត ។ រួចតិឈាមដែលរត់ខុសធម្មតា គឺបេះដូងដែលវាយលឿនជាងធម្មតា គឺ បទោសពេញតនាដែលជ្រួលខ្លួលលើសធម្មតាក្នុងរូបយុវជនទាំងពីរ ។

*កណ្ណា ! ឱ កណ្ណា !* នារីភ្លេចអស់ហើយ ! ផ្កាទៅដោយផ្កា ផុតុកទៅដោយផកុត ដីទៅដោយដី ធម្មជាតិទៅដោយធម្មជាតិ នៅ សល់តែវត្ថុមួយគឺបង និងប្អូនប៉ុណ្ណោះ ដែលអ្នកផងស្គាល់ឈ្មោះហៅថា សេចក្ដីស្នេហាឬរាគៈ ឬភ្លើងមេត្រី ។

នាងទេវីនិយាយខ្សឹបៗ ដាក់ត្រចៀកបុរសថា :

- បង ! បងមាននួ ! បង !

បុរសឈ្មោះមាននួធ្វើមិនឮ លូចញញឹមនៅក្បែរត្រចៀកនាងវិញ ។ នាងនិយាយបន្តទៀត :

- បង ! បងមាននួ !

បុរសលើកស្ត្រីឡើងឲ្យអង្គុយ ។ អ្នកសើចរកនាងឃើញធ្មេញស ស្អុសយកប្រាមដៃចាប់ចង្កានាងដោយមេត្រី រួចឆ្លើយតិចៗ ទៅវិញ :

- បងស្រឡាញ់អូនណាស់ ! បងមិនចង់លែងអូនឲ្យផុតពីទ្រូងដៃបង ទេបងចង់តែនៅឲ្យជាប់សាច់មួយជាមួយអូន ។

នារីបែបអៀន មុខឡើងក្រហម ញញឹមចុងមាត់តបទៅវិញ ។ បុរសចាប់បង្វិលខ្លួននាងយ៉ាងលឿន ខ្លួននាងក៏បានធ្លាក់មកជាប់ ទឹងដើមទ្រូងប្រុសជាទីស្នេហា ។

ក្នុងសន្ទុះនេះ ស្ត្រីផ្អេកក្បាលទាងលើស្មាមាននួជាគូជីវិតយ៉ាង



ស្និទ្ធស្នាល ។ ដៃបុរសឱបរឹតចង្កេះនាង ។ ដៃនាងអង្អែលដៃបុរស ។ នាងហាក់ចាត់ខ្លាសចន្តិចដែរ ដោយនៅមិនទាន់ស្គាល់ចិត្តបុរសអ្នកមុនពេក ។ ស្រីពីតានិយាយដោយត្រៀបត្រាថា :

- ប្អូនក៏ស្រឡាញ់បងដែរ . . . អ៊ុំ ទេ ! ប្អូនស្រឡាញ់បងណាស់ បុរសឆ្លើយកាត់ដោយម៉ឺងម៉ាត់ថា :

- អូនដឹងទេ ហេតុអ្វីបានជាអូនស្រឡាញ់បង ?

នាងទេវីខ្វល់ខ្វាយក្នុងចិត្តក្រៃពេក នាងគ្រវីក្បាលដកដង្ហើមធំ ឆ្លើយដោយមានសំឡេងស្រទន់ស្រងាត់វិញថា :

- ហ៊ឺ ! ប្អូននិយាយមិនបានអស់ពីចិត្តទេ ។ ប៉ុន្តែបើនិយាយឲ្យ ខ្លីប្អូនស្រឡាញ់បង ពីព្រោះស្រឡាញ់ៗ ប៉ុណ្ណោះឯង ។

មាននួមានចិត្តត្រេកអរអាណិតស្រី។នាងទេវីលើកដៃឡើងអង្អែលថ្ពាល់ បុរសជាទីស្នេហា ។ នាងនិយាយមួយៗថា ·

- ប្អូនស្រឡាញ់បង ពីព្រោះបងមានលក្ខណៈពេញជាមនុស្ស ។

- ពេញយ៉ាងណា ?

- គឺបងជាខ្មែរ បងស្រឡាញ់ជាតិខ្មែរ បងស្រឡាញ់អ្នកស្រុកខ្មែរ បងធ្វើការរកប្រយោជន៍ឲ្យខ្មែរ បងហ៊ានប្តូរជីវិតនឹងខ្មែរ បងហ៊ានស្លាប់ នឹងខ្មែរ បងមិនប្រកាន់កិច្ចការ មិនថាការណាៗជាការណា បងមិនយក រឿងបុណ្យស័ក្តិមកធ្វើជាគ្រឿងបំពុលខ្លួន បងមិនយករឿងទ្រព្យសម្បត្តិមក សង្កត់ខ្លួន បងមិនបណ្ដោយខ្លួនទៅនឹងរឿងស្រី ស្រា ល្បែង ទៅ។ បងជាមនុស្ស ថ្លៃថ្លាណាស់ . . . ប្អូនសុំទោស ប្អូននិយាយមិនអស់ទេ ។

បុរសញញឹមរួចឆ្លើយវិញថា ៖

- ក្នុងលោកនេះ មានតែប្អូនមួយទេ ដែលចេះពិនិត្យមើលហើយស្គាល់តម្លៃពិតៗ របស់មនុស្ស ។ បងស្រឡាញ់ប្អូន ពីព្រោះតែអូនមានចិត្តខ្ពស់មែននេះ ។ សព្វថ្ងៃនេះ មានខ្លះគេស្រឡាញ់មនុស្ស ដោយមនុស្សនោះមានបុណ្យស័ក្តិទ្រព្យសម្បត្តិ ចេះធ្វើបុកធំ ចេះក្បួនក្បាច់ ចេះដេកនៅស្ងៀមដោយឥតធ្វើការ ចេះបរិភោគម្ហូបឆ្ងាញ់ ដោយឥតចាំបាច់ធ្វើការបង្កើនផលឲ្យបានច្រើន ចេះវោហារអាងអួតខាងជេរស្តី ខាងបញ្ឆោត ចេះមួលបង្កាច់ ។ ម៉្លោះហើយអ្វីដែលខុសទៅជាត្រូវ ត្រូវទៅជាខុស អាក្រក់ទៅជាល្អ ល្អទៅជាអាក្រក់ បាត់អស់យុត្តិធម៌សីលធម៌មនុស្សធម៌ ។ ម្យ៉ាងទៀត បងដែលស្រឡាញ់អូននេះគឺស្រឡាញ់ព្រោះតែអូនក្រ ។ បងដឹងថា គឺមកពីអូនក្រនេះហើយបានជាឪពុកបងមាន ។ ទ្រព្យដែលអូនត្រូវមាន បានទៅអ្នកមានទៅវិញ ។ និយាយដូច្នេះ បងខ្មាសចិត្តអាណិតដល់ជនអ្នកក្រទាំងអស់គ្នាណាស់។សព្វថ្ងៃបងឲ្យតែនឹងគំនិតលោភលន់ទៅសោះទាំងនោះ ដើម្បីសេចក្តីសុខនិងសេចក្តីចម្រើនដល់អ្នកទាំងអស់គ្នា ។ ហេតុនេះ ចូរអូនត្រៀមទុកក្នុងចិត្ត ហើយចាំជានិច្ចថា ក្នុងជាតិនេះយើងស្រឡាញ់គ្នា ព្រោះយើងមានចិត្តទូលាយខ្ពស់ដូចគ្នា។យើងស្រឡាញ់គ្នា ព្រោះយើងមានចិត្តស្រឡាញ់គេឯទៀតដូចគ្នា ពោលគឺយើងសាងសុខរបស់យើងជាមួយសុខរបស់អ្នកឯទៀតពុំមែនលើទុក្ខរបស់អ្នកឯទៀតទេ ។ អូនយល់ទេ ?

- ចាស ! យល់ហើយ បងនិយាយពីរោះស្តាប់ណាស់ ។ ក្នុងជាតិនេះប្អូនសុំតែរស់ជាមួយបងទេ ។ ប្អូនមានចិត្តដូចបង គឺស្អប់ស្រីដែលចាំតែទីពឹងលើគេ ធ្វើការមានចៅហ្វាយបង្គាប់ រួចសប្បាយតាមបុណ្យគេប៉ុណ្ណោះ ។ ប្អូនយល់ថា កើតមកជាមនុស្សត្រូវធ្វើការដើម្បីរស់។មនុស្សត្រូវតស៊ូខ្លាំងសំអាតចិត្ត គឺមិនតាំងខ្លួនជាបញ្ញើក្អែក ឬ ជា ឈ្លើង ដែលរស់តែដោយសារគេនោះទេ ។ មនុស្សត្រូវរកកិត្តិយស រកសេចក្តីថ្កុំថ្កើងរកសេចក្តីថ្លៃថ្នូរ អំពីការងារដែលខ្លួនធ្វើនេះឯង ។ ប្អូនរីករាយនឹងរស់ជាមួយបង ព្រោះបងមានគំនិតដូចប្អូន ។ តែប្អូនសុំចិត្តបងមួយ . . .

- គឺអ្វី ?

- គឺកុំទុកប្អូនជាគ្រឿងសម្រាប់បងសប្បាយ ជាវត្ថុសម្រាប់ផ្គាប់ផ្គុនចិត្តបង ជាគ្រឿងសម្រាប់លំអ ឬ សម្រាប់បម្រើបង . . .

- ទេៗ អូនជាមនុស្សដូចបងដែរ . . .

- ប្អូនជាស្រី ប្អូនពុំមែនមិនពឹងបងជាប្រុសនោះទេ ។ ប្អូនពឹង រួចត្រូវការយ៉ាងដាច់ខាតនឹងពឹង ។ តែប្អូនសុំបញ្ជាក់ថា ប្អូនពុំពឹងដូចគេទេ។ ប្អូនពឹងឲ្យបងជួយបណ្តុះបណ្តាលប្អូនឲ្យដឹងឲ្យចេះឲ្យស្គាល់ផ្លូវត្រូវ ផ្លូវល្អ ផ្លូវចម្រើនប៉ុណ្ណោះឯង ។ ស្តាប់បានទេ ?

- មានក្តីពេញចិត្តពេកនឹងសំដីនារីជាសង្សារ អ្នកពុំឆ្លើយភ្លាមទេ អ្នកនទៅថើបថ្ពាល់ស្រីដែលនៅជិតនឹងច្រមុះខ្លួនស្រាប់ ។ នាងទើបស្រៀវខ្លួនខ្លាចគេ នាងចង់រួចខ្លួនចេញពីបុរសវិញ តែអៀនពេករកធ្វើទៅមិនរួច។ នាងរកបានតែកំប្លែងលេងថា ៖

- បង កុំទុកប្អូនដូចផ្កាណា ! ថើបរួចគ្រវាត់ចោលនោះ ។

- បងថើបអូន ! ព្រោះស្រឡាញ់អូនទេ ។

- ចុះឈ្មោះ បងអត់ស្រឡាញ់អ្នកឯទៀតទេ ?

- អ្នកឯទៀត បងស្រឡាញ់ជាមិត្ត ចំណែកអូន បងស្រឡាញ់ជាប្រពន្ធរាទុកសន្យាផ្លាយណាស់ណា ! ។ បើដូច្នេះ មានតែអូនទេដែលបងដើរថើបគេឯងតែការសារលទៅឬ ?

- ទេ ៗ ៗ មិនបានជាដាច់ខាត . . .

- ចូរអូនកុំទុកបងជាប្រុសផ្កាមាសណា ! ដោងទុកបងត្រឹមជាមាសបានហើយ ។

- បងជាពេជ្រ ។

- អូនជាទាំងត្រាប់ ។

— ខ្ញុំមិនមែនជាអ្វីទាំងអស់ ខ្ញុំថ្ងៃជាងនោះទៅទៀត ខ្ញុំជាមនុស្ស។

- បងជាមនុស្សដែរ ។

ក្នុងពេលនោះ សូរស្ពៃលាន់ឮឡើងទូងៗ ទៅលើគេហដ្ឋានព្រះកម្ពុត។ មានអ្នកដើរតើតមើលទៅខាងទិសដែលស្គរគំមកដល់ ។ នាងទៅក៏ក្រោកងាកមើលតាម ។ មានអ្នកនិយាយទៅកាន់នាងថា :

- បងសូមលាអូនសិន ដល់ម៉ោងគេប្រមូលទ័ពហើយ ចាំអាទិត្យក្រោយសឹមជួបគ្នាទៀត ។

អ្នកសើចយ៉ាងស្រស់ដាក់នាង ។ នាងសើចយ៉ាងស្លូតដាក់អ្នកដោយមិនចង់ឲ្យឃ្លាតសោះ ។ មានអ្នកស្ទុះឃើញចិត្តនាង ។ អ្នកចាប់ដៃនាងទាំងពីរច្របាច់យ៉ាងខ្លាំងនបថើបជាចុងក្រោយបង្អស់ រួចនាងទៅ



ឈរមើលមុខសង្សារដែលចេញខ្លួនមួយៗ ចេញពីនាងទាំងស្ដាយ ។ នារីខ្លាចស្បាក្នុងចិត្តជាពន់ពេក ។ នាងស្រែកតិចៗ ផ្ដាំថា :

- បង ! បង ! យប់នេះពេលអធ្រាត្រសុំជួបនឹងបងមួយភ្លែតត្រង់ក្រោមដើមពោធិ៍ធំជិតខ្ទមអ្នកតា ។

បុរសញញឹមដាក់នាង ងក់ក្បាលទទួលខ្សឹបថា :

- យប់នេះអធ្រាត្រក្រោមដើមពោធិធំ ។

កុំខានណា !

- បាទ ! . . . កុំខានណា !

- ចាំ !

ថាហើយ បុរសស្ទុះភ្លៀតរត់ឆ្ពោះតម្រង់ទៅទាំងគួងបាត់ទៅ ។ នាងកញ្ញាឈរមើលតួសង្សារយ៉ាងរំភើបញាប់ញ័រក្នុងដួងចិត្ត ។ នាងងាកចេញហាក់អស់កម្លាំងហោរទន់ដៃទន់ជើង ដេកដោងៗ ក្នុងខ្លួន ។ នាងដើរមួយៗ ទៅរើសផ្កាដែលនាងបេះចងទុកលើស្មៅ ។

ដើរចេញពីទីស្នេហាបានប្រមាណឆ្ងាយជាងមួយហាទ បុរសម្នាក់មានស្លៀកពាក់ប្រដាប់ដោយគ្រឿងជាធាយទាហានសារុនទៅចង្កេះ រួបដើតស្ទុះពីគុម្ពផ្កាមួយមកចាប់នាងទៅពីក្រោយ ។ ស្រីភ្ញាក់ខ្លួនស្ទើរភ្ញាក់ស្មារតី ។ នាងប្រឹងយ៉ាងខ្លាំងរស់ទំហឹង ចងចិញ្ចៀន ភ័យផង បបូរមាត់ស្លេកស្លាំង ។

ក្នុងមួយវិនាទីនោះ នាងក៏បានរួចពីក្រញាំដៃនៃបុរសថ្មី ។ បុរសសើចក្អាកក្អាយ ដោះមួកចំនាត់នាងយ៉ាងគំប្រុងអស់ពីចិត្ត ។

នាងទេវីខាំធ្មេញក្រឹត សំឡក់បុរស មុខនាងដែលស្វាំង ក៏ប្រែ
ជាក្រហមក្លាម ។ នាងនិយាយដោយសង្កត់ពាក្យទៅកាយមុខដែលថែមក
ថា :

- យី ! លោកកាមា ! ចៀសចេញពីទីនេះឲ្យឆាប់ ។

នាងចង្អុលមុខបុរសដោយបន្តវាចាថា :

- នែ ! មុខលោកឯង កុំមកប៉ះសាច់ខ្ញុំណា ! ម៉ះមិនបានទេ ។
ទៅ ។ ស្អប់មុខណាស់ ។

បុរសឈ្មោះកាមា ពេលបាត់សើចយ៉ាងវែង ច្រត់ចង្កេះមើលនារី
ដែលខឹងហើយពោលតបដោយសំឡេងក្អួលខ្ទាំងថា :

- ស្រីដែលមានរូបល្អដូចអូន មិនគួរមានចិត្តអាក្រក់សោះ ។
ថាហើយ កាមាសើចក្អាកក្អាយលាន់ឮរំពង ។

- យី ! អីលោកហ៊ានហៅខ្ញុំអូនផង ? ខ្ញុំជាប្អូនលោកពីកាល
ណា ? មនុស្សអីក៏មានចិត្តឫស្យា មុខក្រាស់ម៉្លេះ ?

ថាហើយ នាងច្រត់ដៃនឹងចង្កេះខាង សម្លឹងមុខបុរសគ្មានប្រហែល
ឡើយ ។ កាមាសើចដដែល ។

- បើមិនឲ្យខ្ញុំហៅអូន តើឲ្យខ្ញុំហៅអីវិញ ។ ហៅបង ? ហៅអ្នក
បង ? ហៅមិនកើតទេ ។

នាងទេវីឮសំដីចុងក្រោយនេះ នាងស្មានក្នុងចិត្តថា ប្រហែលបុរស
នេះ ឃើញនាង និងមានថ្មហើយ ពីព្រោះកាមាត្រូវជាក្លូនបង្កើតរបស់
មានទុ ។ នាងទំនប់សេចក្តីអៀនខ្មាស ប្រឹងធ្វើទឹកមុខដដែល ។

- យី ! ចំណាស់ប៉ុនខ្ញុំ លោកហៅខ្ញុំបងមិនបានឬ ?

- ហៅមិនបាន ពីព្រោះខ្ញុំស្រឡាញ់អ្នកយូរមកហើយ ។ ខ្ញុំចង់
បានអ្នកជាប្រពន្ធខ្ញុំ ។ ខ្ញុំប្រាថ្នាលើកតម្កើងអ្នក ឲ្យខ្ពស់ផុតផុសនារីដែល
មាននៅលើលោកនេះ។ ខ្ញុំចង់ឲ្យអ្នកថ្កុំថ្កើងរុងរឿងដោយសារស្នាដៃខ្ញុំ ។

- មិនបាច់និយាយច្រើនទេ ! ខ្ញុំអរគុណណាស់ ខ្ញុំមិនត្រូវការ
សេចក្តីស្រឡាញ់របស់លោកទេ ។ ខ្ញុំមិនត្រូវការឲ្យលោកលើកតម្កើង
ខ្ញុំទេ ពាក្យថោក គំនិតទាប ខ្ញុំមិនចង់ស្តាប់លោកទេ ។

បុរសឡើងក្រហមស្លឹកត្រចៀក ។ ដោយស្រឡាញ់នាងទេវីពេក
កាមាមើលមុខនាងឃើញល្អអ្វីក៏ល្អម៉្លេះទេ ទោះកំពុងខឹងក្រញូវមុខម៉្លេះ
ក៏នៅតែល្អ ។ សំឡេងពីរោះអ្វីក៏ពីរោះម៉្លេះ ទោះគំហកជេរលត្ថះ
ប៉ុណ្ណោះហើយក៏នៅតែពីរោះ ។ អ្នកមើលមុខនាងដោយអង្វរ ហើយ
ពោលថា :

- ខ្ញុំទាប អ្នកខ្ពស់ បានជាខ្ញុំស្រឡាញ់អ្នក ។ ខ្ញុំសូមចិត្តអ្នកចុះ
កុំខឹងអ្វីនឹងខ្ញុំ ។ ដោយស្រឡាញ់អ្នកពេកហើយ បានជាអញ្ជាញខ្ញុំមិញ
ខ្ញុំស្ទុះមកឱបអ្នក ។ សូមទោសអ្នកចុះកុំប្រកាន់ខ្ញុំ ។ ខ្ញុំនេះពិតជាស្រឡាញ់
អ្នកមែន ។ ថ្ងៃនេះខ្ញុំចង់និយាយនឹងអ្នកឲ្យបានវែង ដើម្បីអ្នកយល់ ...

- ខ្ញុំមិនបាច់ស្តាប់លោកទេ។ខ្ញុំមិនចង់ស្គាល់ មិនចង់យល់លោកទេ។

កាមាខឹងខ្លួលក្នុងចិត្ត ដោយមើលឃើញជាក់ថា ចម្រៀវជាក់មិន
បានការ ។ អ្នកខាំធ្មេញដើរចូលទៅរកនាងប្រាថ្នាតែតកំហែងចាប់ដោយ
កម្លាំងតែម្តង ។ នារីសម្លឹងបុរសយ៉ាងកាចបំផុត ។ កាមាចុចង៉ក់ ។ នាង

នាងតបថា :

- កាមា ! កាមា ! កាមា ! កុំចូលជិត ! បើចូល មានតែស្លាប់ និងរស់ប៉ុណ្ណោះ ! ខ្ញុំមិនជឿយមួយជំហានទេ ។ ឈប់ ! កាមាចេះតែនិយាយនឹងយើងណាស់ ឈរឲ្យស្ងៀមមួយកន្លែងចម្ងាយបីម៉ែត្រពីយើង ។ អើ ! ធ្វើយ៉ាងហ្នឹងបានហៅថាពេញជាកូនប្រុស ។ ឥឡូវនិយាយមកចុះ បើពេញជាកូនព្រះគម្ពុតមែន ខ្ញុំស្តាប់ ។

- អ្នកប្រាប់ទេ ? ខ្ញុំស្រឡាញ់អ្នកយូរណាស់មកហើយ ។ ឪពុកខ្ញុំព្រះកម្ពុត ជាចៅហ្វាយខេត្តដែលមិនឆ្ងាត់សិរីសោភ័ណនេះ ។ ខ្ញុំអាចសុំឲ្យឪពុកខ្ញុំចូលដណ្តឹងអ្នកបាន ។ តែខ្ញុំត្រូវតែចង់ដឹងចិត្តអ្នកថែមបន្តិចទៀតទេ បានជាខ្ញុំតែងតែរៀបតាំងការចង់ជួបនឹងអ្នក ដើម្បីយើងនិយាយគ្នាឲ្យដឹងបើមិនដឹងចុងបន្តិច ។ ឪពុកខ្ញុំប្រាកដជាស្រឡាញ់អ្នកដែរ ពីព្រោះគាត់បាននិយាយដំណាលពីអ្នករឿយ ៗ ណាស់ ។

- ឪពុករបស់លោកដំណាលពីគ្រប់ស្រីដែលមានរូបល្អ ។ នេះជាការធម្មតាទេ ។

- ទេ ! លោកប្រហែលចង់បានអ្នកជាកូនប្រសាដែរ ។

- ប្រហែលជាចង់បានខ្ញុំយកទៅធ្វើប្រពន្ធខ្លួនឯងទេដឹង ? ឪពុកលោកជាមនុស្សមកពីអវិចី ប្រពន្ធរាប់សិបនាក់ ល្ងួចកូនគេ ល្ងួចប្រពន្ធគេ ។

- យីអ្នក ! ខ្ញុំនិយាយមិនស្តាប់ បានតែបងមានធ្មប់ ទើបនិយាយស្តាប់បាន ?

- អើ ! ខ្ញុំស្តាប់តែមានខ្លួនពិតប្រាកដមែន ។ មានធ្លាក់ចូលស្បារ





ខ្ញុំ ជាប្ដីខ្ញុំពេញទី ។ អើ ! អើ ! បើកាយាឯងជាប្អូនមានទុក្ខ ហើយនឹងថា មានទុក្ខជាប់អកាយាឯងស្រឡាញ់ខ្ញុំហើយ ម្ដេចក៏កាយាឯងមកស្រឡាញ់ខ្ញុំទៀត ? ឬចង់ឲ្យគាត់មានទុក្ខជាប់ជាប់ស្ដើត ? លោកក្បត់ចុះ តែខ្ញុំ ។ មិនក្បត់ទេ ។ កាយា ! ខ្ញុំសូមលោកកុំស្រណោះទៀតទៅ មិនខ្វះទេស្រីល្អ ។ នោះ ។ តែកុំធ្វើផ្ដេសផ្ដាសឲ្យបាក់បែកគ្រួសារយើងទេ ។ ទៅ ! កាយា អញ្ជើញទៅចុះ ។

កាយាវិលត្រឡប់ទៅទៀត អ្នកសំឡុតនាងទេវីស្មើរឆ្ងុះពាំថី ។ ឡប់តាំងពីមួយប៉ោតមកលើផ្លូវចិត្តអ្នកផ្ដួចផ្ដើមសង្សារ ។ យ៉ាងហើស អ្នកបែរមុខចេញស្ទុះលោតតាត់ផ្លូវផ្កាពីមួយទៅមួយ តម្រង់ទៅកេមាផ្ទាន ព្រះកម្ពុតទុក ។

នាងកញ្ញាទេវីបានធ្លាប់ជួបនាទីរើមម្ដង ធុញចិត្ត ឈរមើល កាយាដែលលាត់ទៅ ។ អស់កម្លាំងហោរ នារីដើរមួយៗ ទៅកាន់ផ្ទះនាង ។

x x

x



# រាត្រីស្ងាត់

រាត្រីស្ងាត់ ខ្យល់បក់ល្ហិច ៗ ល្ហើយហើយ ។ ស្លឹកឈើទាំងឡាយ ត្រូវនឹងរាវែផាដែលរត់សង្វៀម ។ ផ្ទុំកើតជាផ្គរគន្ធើមួយយ៉ាងមនោរម្យ ។

លើមេឃ ព្រះចន្ទទោលនេត្រាប្រកបដោយមេឃាមកលើពិភពលោក ធ្វើឲ្យទេសភាពមាណាខេត្តសិរីសោភ័ណក្លាយទៅជាភាពយន្តមួយយ៉ាងគំសត់ ។ ផ្កាយភ្លឺព្រិច ៗ ព្រោងព្រាតកណ្ដាលផ្ទៃពពកខៀវស្រងាត់ ។

ក្នុងក្នុងផ្ទះ នាងទេវីអង្គុយបត់ជើងនៅស្ងៀមមុខគ្នូចចង្កៀងខ្លាញ់មួយ ។ ស្ទួរគ្រាំគ្រាំ ។ តិច ។ ដឹងចក់យំថី ។ នៅលើផ្លូល ។

នារីស្រៀវខ្លួនខ្ញាកនឹកដល់ប្រុសជាទីស្នេហា ។ ចិត្តនាងរមួលរមួលខ្លាំង ។

ពន្លឺចង្កៀង ធ្វើឲ្យឃើញរង់មុខនាងក្រឡង់ដូចរង់ព្រះចន្ទ ។ កណ្ដាលរង់នេះ ភ្នែកពីរបញ្ចាំងរស្មីយ៉ាងរលង់ ។ ស្បែកបបូរមាត់ឃើញស្ដើតគួរឲ្យចង់អង្អែលលេង ។

នៃនាងធ្វើការ ចិត្តនាងហើចហើរទៅឆ្ងាយ ៗ ពីរហាត់ ឆ្ងាយពីផ្ទះ ឆ្ងាយពីរបង ឆ្ងាយផល់ដើរពាធី ដែលហាត់ទៅជើងមេឃផុះតែតង់ៗ